**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥២៦ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០០២

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើត និង តែងតាំងភ្នាក់ងារបើកផ្តល់ សំរាប់បើក បៀវត្ស និង ប្រាក់អត្ថាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ នៅក្រសួងអប់រំ យុវជន និង កីឡា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត /១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩

-បានឃើញព្រះរាជក្រមលេខ នស/ រកម /១២០១ /១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

-បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន ៤

## សំរេច

ប្រការ១ : ប្រាក់បៀវត្សមន្ត្រីរាជការ និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ត្រូវបើកផ្តល់តាមរយៈ " ភ្នាក់ងារបើកផ្តល់

ប្រការ២ :ត្រូវបានតែងតាំង÷

-កញ្ញា ទាវ សុភា ឋានៈអនុប្រធានការិយាល័យរដ្ឋបាល នៃ នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវបានជាភ្នាក់ងារបើកផ្តល់

-លោក សេង រ៉ាឌុន ជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ៣:កញ្ញា ទាវ សុភា និង លោក សេង រ៉ាឌុន ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើ នៅរតនាគារជាតិ ដើម្បីទទួលមូលនិធិ សំរាប់យកទៅបើកបៀវត្ស និង ប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ជូនមន្ត្រីរាជការ ។

ប្រការ៤:របបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ៥:ភ្នាក់ងារបើកផ្តល់ត្រូវ ទទួលខុសត្រូវផ្ទាល់ចំពោះ ប្រាក់កាស និង មូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ៦:សេចក្តីសំរេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៧:អគ្គលេខាធិការ,នាយកខុទ្ទកាល័យ,ប្រធានរតនាគារជាតិ,ប្រធាននាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច,ប្រធាននាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងអប់រំ យុវជន និង កីឡា ព្រមទាំង កញ្ញា ទាវ សុភា និង លោក សេង រ៉ាឌុន ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ -

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

តុល.ឡាះ

កន្លែងទទួល :

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ៧

"ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ